# អនុក្រឹត្យ

## ស្តីពី

# ការជួលដែននេសាទទឹកសាប
# និងសមុទ្រអោយធ្វើអាជីវកម្ម

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

## អនុក្រឹត្យ/២៦ អនក្រ/០៩ ១សកា ១៩៨៩/ស្តីពី ការជួលដែននេសាទទឹកសាប និងសមុទ្រអោយធ្វើអាជីវកម្ម

ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា

- បានឃើញ ច្បាប់ស្តីអំពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២

- បានឃើញ ក្រឹត្យ-ច្បាប់លេខ ០៧ក្រច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា.

- បានឃើញ ក្រឹត្យ-ច្បាប់លេខ ៣៣ក្រច ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យ ជលផល.

- តាមសំណើរបស់ក្រសួងកសិកម្ម.

### សំរេច

**មាត្រា១:** ការជួលដែននេសាទទឹកសាបនិងសមុទ្រ ត្រូវបានកំណត់ដូចខាងក្រោម:

១. ការជួលឡូត៍នេសាទត្រូវអនុវត្តដោយការដេញថ្លៃជាសាធារណៈ ។

២. ការជួលដែននេសាទដែលត្រូវការពារអោយធ្វើនេសាទសិប្បកម្ម ត្រូវកំណត់យកតាមប្រភេទ និងទំហំឧបករណ៍នេសាទ ។

៣. ការជួលដែននេសាទសមុទ្រអោយធ្វើនេសាទដោយឧបករណ៍នេសាទ ដែលអាចអនុញ្ញាតអោយប្រើត្រូវកំណត់តាមប្រភេទ និងទំហំឧបករណ៍នេសាទ ឬតាមកំលាំងសេសនៃមធ្យោបាយនេសាទ ។

ការជួលដែននេសាទនៅត្រង់ចំណុច២ និងចំណុច៣ ខាងលើនេះមិនអនុវត្តចំពោះការធ្វើនេសាទជាលក្ខណៈគ្រួសារទេ ។

**មាត្រា២:** ប្រាក់ឈ្នួលដែននេសាទទឹកសាបនិងសមុទ្រ ត្រូវបានគិតរួមបញ្ចូលទាំងពន្ធអាជីវកម្មដែលមានចែងក្នុងក្រឹត្យ-ច្បាប់លេខ ២៣ ក្រច ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ១៩៨៥ តែម្តង ។

នាយកដ្ឋាននិងការិយាលយជលផលខេត្ត ក្រុងហើយនិងសាខា ឬការិយាល័យពន្ធខេត្ត ក្រុងត្រូវមាន ភារកិច្ចសហការគ្នាទារថ្លៃឈ្នួលដែននេសាទ និងប្រាក់ពន្ធគ្រប់ប្រភេទពីអ្នកនេសាទទាំងអស់តាមការកំណត់ របស់រដ្ឋលើកលែងតែអ្នកនេសាទជាលក្ខណៈគ្រួសារ ។

**មាត្រា៣:** ក្រៅពីឡូត៍នេសាទដែលក្រសួងកសិកម្មបានទុកអោយអង្គភាពនេសាទរបស់នាយកដ្ឋានជលផល ឬការិយាល័យជលផលខេត្ត ក្រុងសំរាប់ធ្វើអាជីវកម្ម និងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសខាងជលផល ឡូត៍នេសាទដែលនៅសល់ពីនេះត្រូវជួលអោយឯកជនធ្វើអាជីវកម្ម ដោយធ្វើការដេញថ្លៃជាសាធារណៈ ។

**មាត្រា៤:** ដើម្បីដេញថ្លៃនាយកដ្ឋានជលផលត្រូវធ្វើសេចក្តីជូនដំណឹងជាសាធារណៈដោយបិទផ្សាយនៅនាយកដ្ឋានជលផល ការិយាល័យជលផលខេត្ត ក្រុងមន្ទីរគណៈកម្មាធិការប្រជាជនខេត្ត ក្រុង ស្រុក ឬ ខណ្ឌ និងឃុំ ឬសង្កាត់ដែលជាប់ឡូត៍នេសាទអោយបានយ៉ាងតិច ៣០ថ្ងៃមុនពេលដេញថ្លៃហើយត្រូវ បញ្ជាក់:

- ទីតាំងឡូត៍នេសាទដែលត្រូវដេញថ្លៃ
- ថ្លៃឈ្នួលឡូត៍នេសាទដែលបានកំណត់ដាក់អោយដេញថ្លៃ
- ប្រាក់ធានាបណ្តោះអាសន្ន
- ទីកន្លែង និងពេលវេលាដែលត្រូវដេញថ្លៃ

**មាត្រា៥:** ការដេញថ្លៃឡូត៍នេសាទ ត្រូវប្រព្រឹត្តទៅនៅមន្ទីរគណៈកម្មាធិការប្រជាជនខេត្ត ក្រុងហើយត្រូវស្ថិតនៅក្រោមការចាត់ចែងរបស់គណៈកម្មការដេញថ្លៃឡូត៍នេសាទដែលចាត់តាំងឡើងដោយប្រធានគណៈកម្មាធិការប្រជាជនខេត្ត ក្រុងហើយដែលមានសមាសភាពដូចខាងក្រោម:

១. ប្រធានគណៈកម្មាធិការប្រជាជនខេត្ត ក្រុង សាមី ឬតំណាង ជាប្រធាន

២. ប្រធាននាយកដ្ឋានជលផល ឬតំណាង ជាអនុប្រធាន

៣. ប្រធានគណៈកម្មការផែនការខេត្ត ក្រុង ឬតំណាង ជាសមាជិក

៤. ប្រធានមន្ទីរហិរញ្ញវត្ថុខេត្ត ក្រុង ឬតំណាង ជាសមាជិក

៥. ប្រធានមន្ទីរកសិកម្មខេត្ត ក្រុង ឬតំណាង ជាសមាជិក

៦. ប្រធានធនាគារខេត្ត ក្រុង ឬតំណាង ជាសមាជិក

៧. ប្រធានសាខា ឬការិយាល័យពន្ធខេត្ត ក្រុង ឬតំណាង ជាសមាជិក

៨. ប្រធានការិយាល័យជលផលខេត្ត ក្រុង ឬតំណាង ជាសមាជិក

**មាត្រា៦:** ពលរដ្ឋកម្ពុជាគ្រប់រូបលើកលែងតែកម្មាភិបាល និយោជិតរដ្ឋ មានសិទ្ធិចូលដេញថ្លៃឡូត៍នេសាទនៅខេត្ត ក្រុងណាក៏បាន។ អ្នកចង់ចូលដេញថ្លៃត្រូវដាក់ពាក្យសុំដេញថ្លៃធ្វើអាជីវកម្មឡូត៍នេសាទយ៉ាងយឺតបំផុត ១០ថ្ងៃមុនពេលដេញថ្លៃនៅការិយាល័យជលផលខេត្ត ក្រុងដែលមានឡូត៍នេសាទដាក់អោយដេញថ្លៃ។

ពាក្យសុំខាងលើនេះត្រូវមានសំណុំលិខិតភ្ជាប់ជាមួយដូចខាងក្រោម:

១. ប្រវត្តិរូបសង្ខេបដែលត្រូវបានរដ្ឋអំណាចឃុំ ឬសង្កាត់បញ្ជាក់ទទួលស្គាល់។

២. កិច្ចសន្យាគោរពអោយបានត្រឹមត្រូវតាមបទបញ្ជាទាំងឡាយដែលមានចែងក្នុងសៀវភៅបន្ទុក និងក្នុងលិខិតអនុញ្ញាតអោយធ្វើអាជីវកម្មក្នុងឡូត៍នេសាទ។

៣. បង្កាន់ដៃបង់ប្រាក់ធានាបណ្តោះអាសន្នចំនួនយ៉ាងតិច ១/៣ នៃថ្លៃឈ្នួលឡូត៍ដែលបានកំណត់ដាក់អោយដេញថ្លៃ។

៤. កិច្ចសន្យាបង់ប្រាក់ធានាស្ថាពរអោយបានគ្រប់ចំនួន ២/៥ នៃថ្លៃឈ្នួលឡូត៍ដែលដេញបានយ៉ាងយឺត បំផុត ១៥ថ្ងៃក្រោយពេលដេញថ្លៃ។

៥. កិច្ចសន្យាសុខចិត្តប្រគល់ជូនរដ្ឋនូវប្រាក់ធានាបណ្តោះអាសន្នទាំងអស់ និងសុខចិត្តបង់ពិន័យជូនរដ្ឋស្មើ ៥០ភាគរយនៃប្រាក់លំអៀងរវាងថ្លៃដែលខ្លួនដេញបាន និងថ្លៃដែលដេញបានទាបជាងនៅលើកក្រោយ ក្នុងករណីដែលដេញបានហើយ:

- មិនព្រមចុះហត្ថលេខាលើកំណត់ហេតុដេញថ្លៃ។
- មិនបានបង់ប្រាក់ធានាស្ថាពរ អោយបានគ្រប់ចំនួនក្នុងរយៈពេល ១៥ថ្ងៃក្រោយពេលដេញថ្លៃ។

៦. កិច្ចសន្យាសុខចិត្តប្រគល់ជូនរដ្ឋទាំងអស់នូវប្រាក់ធានាស្ថាពរក្នុងករណីដែលខ្លួនមិនបានគោរពតាមកិច្ចសន្យា ឬបោះបង់ឡូត៍នេសាទចោលមុនពេលបញ្ចប់រដូវនេសាទទី ២ទោះក្នុងល័ក្ខខ័ណ្ឌក៏ដោយ។

ប្រធាននាយកដ្ឋានជលផល ឬតំណាងមានសិទ្ធិមិនអនុញ្ញាតអោយចូលដេញថ្លៃចំពោះជនណាដែល:

- ធ្លាប់ដេញថ្លៃបានហើយ ហើយមិនគោរពតាមកិច្ចសន្យា។

- ធ្លាប់បានប្រព្រឹត្តបទល្មើសជលផល មានលក្ខណៈធ្ងន់ធ្ងរ ឬជាជនមិនរាងចាល ។

ពីរករណីខាងក្រោយនេះត្រូវកំណត់តែក្នុងរយៈពេលពីររដូវនេសាទកន្លងមកទល់ពេលដេញថ្លៃប៉ុណ្ណោះ ។

**មាត្រា៧:** ការដេញថ្លៃឡូត៍នេសាទមួយលើកៗ ត្រូវបានកំណត់សំរាប់អោយធ្វើអាជីវកម្មនេសាទក្នុងរយៈពេលពីររដូវនេសាទជាប់គ្នា ។ ការកំណត់ថ្លៃឈ្នួលឡូត៍នេសាទដែលដាក់អោយដេញ និងការអោយថ្លៃឈ្នួលឡូត៍នេសាទរបស់អ្នកដេញថ្លៃនៅពេលដេញថ្លៃ គឺជាថ្លៃជួលឡូត៍ផង និងថ្លៃពន្ធអាជីវកម្មផងសំរាប់អោយធ្វើអាជីវកម្មក្នុងមួយរដូវនេសាទ គឺរដូវនេសាទទី១ ហើយរដូវនេសាទទី២ បន្ទាប់ក៏ត្រូវអនុវត្តន៏ថ្លៃឈ្នួលឡូត៍ដូចរដូវនេសាទទី១ដែរ ។

**មាត្រា៨:** វិធីដេញថ្លៃត្រូវអនុវត្តដូចខាងក្រោមៈ

នៅពេលចាប់ផ្តើមការដេញថ្លៃឈ្នួលឡូត៍នេសាទនីមួយៗ គណៈកម្មការដូចមានចែងក្នុងមាត្រា៥ត្រូវពិនិត្យសំណុំលិខិតសុំចូលដេញថ្លៃ ហើយត្រូវប្រកាសឈ្មោះអ្នកដេញថ្លៃដែលត្រូវបានអនុញ្ញាតអោយចូលដេញថ្លៃចំពោះជនណាដែលបានបំពេញសំណុំលិខិតគ្រប់គ្រាន់និងត្រឹមត្រូវ ព្រមទាំងប្រកាសទីតាំងឡូត៍នេសាទដែលត្រូវដេញថ្លៃ និងថ្លៃឈ្នួលឡូត៍ដែលបានកំណត់ដាក់អោយដេញ ។ វិធីដេញថ្លៃត្រូវអនុវត្តជាពីរលើកដូចខាងក្រោមៈ

លើកទី១: ជនដែលមានសិទ្ធិចូលដេញថ្លៃ ត្រូវអោយថ្លៃឈ្នួលឡូត៍ដោយសរសេរជាលេខនឹងលាយលក្ខណ៍អក្សរក្នុងស្រោមសំបុត្របិទជិត ហើយជនណាម៉ានអោយថ្លៃខ្ពស់ជាងថ្លៃឈ្នួលដែលបានកំណត់ដាក់អោយដេញត្រូវបានអនុញ្ញាតអោយចូលដេញថ្លៃលើកទី២ ។

លើកទី២: ការដេញថ្លៃត្រូវកំណត់ដោយអុជទៀនដែលអាចឆេះក្នុងរយៈពេលពី ៣នាទី ដល់ ៥នាទីក្នុងទៀនមួយជាបន្តបន្ទាប់ហើយជនដែលមានសិទ្ធិចូលដេញថ្លៃ ត្រូវអោយថ្លៃផ្ទាល់មាត់ដោយឡើងថ្លៃមួយយ៉ាងតិចបំផុតត្រឹម ៥.០០០៛០០ ចាប់ពីថ្លៃដែលខ្ពស់ជាងគេនៅលើកទី ១ ឡើងទៅ ។

ក. ទៀនទី១: ជនដែលបានអោយថ្លៃ នៅមុនពេលទៀនទី ១ រលត់នោះត្រូវបានអនុញ្ញាតអោយចូលដេញថ្លៃនៅទៀនទី២ ។ ចំពោះជនដែលមិនបានអោយថ្លៃសោះត្រូវបញ្ឈប់មិនអោយចូលដេញថ្លៃនៅទៀនទី ២ ទៀតទេ ។

ខ. ទៀនទី២: ជនដែលបានអោយថ្លៃខ្ពស់ជាងគេនៅទៀនទី១នោះ អាចអនុញ្ញាតអោយចូលដេញថ្លៃនៅទៀនទី៣។ ចំពោះជនដែលមិនបានអោយថ្លៃសោះត្រូវបញ្ឈប់មិនអោយចូលដេញថ្លៃនៅទៀនទី៣ទៀតទេ។

គ. ទៀនទី៣: ជនណាដែលហ៊ានអោយថ្លៃនៅមុនពេលទៀនរលត់ ខ្ពស់ជាងថ្លៃខ្ពស់ជាងគេនៅទៀនទី១ ទៀនទី២ និងខ្ពស់ជាងគេនៅទៀនទី៣ នោះគណៈកម្មការត្រូវប្រកាសថាជននោះដេញថ្លៃបានជាបណ្ដោះអាសន្ន ដើម្បីរង់ចាំការពិនិត្យ និងសំរេចពីក្រសួងកសិកម្ម។

ក្នុងករណីអោយថ្លៃជាប់មាត់គ្នានៅពេលទៀនទី៣រលត់ គណៈកម្មការត្រូវអោយដេញថ្លៃផ្ទាល់មាត់សារ ជាថ្មីដោយចាប់ផ្ដើមអុជទៀនទី១ ឡើងវិញ។ ក្នុងករណីនេះត្រូវអោយថ្លៃពីថ្លៃដែលជាប់មាត់គ្នានោះ ឡើងទៅ។

**មាត្រា៩:** ជនដែលត្រូវបានប្រកាសថាដេញថ្លៃបានជាបណ្ដោះអាសន្ន ត្រូវបង់ប្រាក់ធានាស្ថាពរដោយគិតរួមទាំងប្រាក់ធានាបណ្ដោះអាសន្នផង អោយបានគ្រប់ចំនួន ២/៥ នៃថ្លៃឈ្នួលឡូត៍ដែលដេញបាន។

ប្រាក់ធានាស្ថាពរនេះ សំរាប់ធានាលើការគោរពកិច្ចសន្យា ហើយអាចផ្ទេរប្រាក់នេះបង់ថ្លៃឈ្នួលឡូត៍បង្គ្រប់នៅចុងរដូវនេសាទទី២តែម្ដង។

**មាត្រា១០:** គ្រប់សំណុំលិខិតសុំចូលដេញថ្លៃ និងកំណត់ហេតុនៃការដេញថ្លៃឡូត៍នេសាទនីមួយៗព្រមទាំងបង្កាន់ដៃបង់ប្រាក់ធានាស្ថាពរ ត្រូវបញ្ជូនទៅក្រសួងកសិកម្មជាបន្ទាន់ដើម្បីពិនិត្យនិងសំរេច។

ក្រសួងកសិកម្មត្រូវចេញសេចក្ដីសំរេចក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ៤៥ថ្ងៃក្រោយពេលដេញថ្លៃ។

**មាត្រា១១:** ត្រូវទុកជាអសារឥតការគ្រប់ការដេញថ្លៃបាន ក្នុងករណីដូចខាងក្រោម:

១. ការដេញថ្លៃឡូត៍ដោយមិនបានធ្វើសេចក្ដីជូនដំណឹង ដូចមានចែងក្នុងមាត្រា៤ ឬដេញថ្លៃខុសពីសេចក្ដីបញ្ជាក់ក្នុងសេចក្ដីជូនដំណឹង។

២. មានភស្តុតាងថាអ្នកដែលដេញថ្លៃបាននោះបានឃុបឃិតជាមួយអ្នកផ្សេងទៀត ឬមានកលល្បិចធ្វើអោយការដេញថ្លៃនោះមានថ្លៃថោក ចាប់ពីពេលដេញថ្លៃរហូតដល់មុនពេលចេញសេចក្ដីសំរេចរបស់ក្រសួងកសិកម្ម។

៣. អ្នកដែលដេញថ្លៃបាននោះមិនបានបង់ប្រាក់ធានាស្ថាពរអោយបានគ្រប់ចំនួនក្រោយពេលដេញថ្លៃ ១៥ ថ្ងៃ។

៤. អ្នកដេញថ្លៃបានរួចហើយបានបោះបង់ឡូត៍នៃសាទចោល នៅមុនពេលបញ្ចប់វគ្គនៃសាទទី២។

ក្នុងករណីខាងលើនេះត្រូវរៀបចំដេញថ្លៃឡូត៍នោះសារជាថ្មី ក្រោយពីបានធ្វើសេចក្តីជូនដំណឹងចំនួន ១៥ ថ្ងៃ។ អ្នកចង់ដេញថ្លៃត្រូវដាក់សំណុំលិខិតសុំចូលដេញថ្លៃយ៉ាងយឺតបំផុត២ថ្ងៃមុនពេលដេញថ្លៃ។

**មាត្រា១២:** ប្រាក់ធានាបណ្តោះអាសន្នត្រូវបានរឹបអូសតាមផ្លូវច្បាប់ ក្នុងករណីដែលជនណាដេញថ្លៃបានហើយមិនព្រមចុះហត្ថលេខាលើកំណត់ហេតុដេញថ្លៃ និងលើសៀវភៅបន្ទុក ឬមិនបានបង់ប្រាក់ធានាស្ថាពរអោយបានគ្រប់ចំនួនក្នុងរយៈពេល ១៥ថ្ងៃក្រោយពេលដេញថ្លៃបាន។

ប្រាក់ធានាស្ថាពរក៏ត្រូវបានរឹបអូសតាមផ្លូវច្បាប់ដែរ ក្នុងករណីដូចមានចែងក្នុងចំណុចទី ៤នៃមាត្រា ១១ ខាងលើ ឬមិនគោរពតាមកិច្ចសន្យា។

**មាត្រា១៣:** ជនដែលដេញថ្លៃឡូត៍នៃសាទបានជាបណ្តោះអាសន្នរួចហើយ មិនអនុញ្ញាតអោយចូលដេញថ្លៃឡូត៍នៃសាទផ្សេងទៀតទេ។

ចំពោះជនដែលមិនទាន់ដេញថ្លៃបាន អាចអនុញ្ញាតអោយចូលដេញថ្លៃឡូត៍ផ្សេងទៀតបានក្នុងករណីដែលជននោះបានបង់ប្រាក់ធានាបណ្តោះអាសន្នខ្ពស់ជាងឬស្មើប្រាក់ធានាបណ្តោះអាសន្នចំនួន១/៣នៃថ្លៃឈ្នួលឡូត៍នៃសាទដែលដាក់អោយដេញថ្លៃ។

ការអនុញ្ញាតខាងលើនេះអនុវត្តចំពោះតែជនណា ដែលបានបង់ប្រាក់ធានាបណ្តោះអាសន្ននៅខេត្តក្រុងដែលមានឡូត៍នៃសាទដែលត្រូវដេញថ្លៃប៉ុណ្ណោះ។

**មាត្រា១៤:** ប្រាក់ធានាបណ្តោះអាសន្នរបស់ជនដែលដេញថ្លៃពុំបាន ត្រូវប្រគល់ជូនវិញជាបន្ទាន់នៅពេលជននោះបានបង្ហាញបង្កាន់ដៃនៃប្រាក់ធានាបណ្តោះអាសន្ន និងលិខិតបញ្ជាក់ពីគណៈកម្មការដេញថ្លៃឡូត៍នៃសាទថាជននោះពិតជាដេញថ្លៃពុំបានមែន។

**មាត្រា១៥:** នៅពេលដេញថ្លៃបើមានឡូត៍ខ្លះដែលគ្មានជនណាហ៊ានអោយថ្លៃតាមឈ្នួលដែលបានកំណត់ដាក់អោយដេញ គណៈកម្មការដេញថ្លៃត្រូវកំណត់ថ្លៃឈ្នួលដាក់អោយដេញសារជាថ្មី ដោយបន្ថោកជាងមុននិងកំណត់ពេលវេលាដែលត្រូវដេញថ្លៃសារជាថ្មី ដែលនឹងប្រព្រឹត្តទៅក្នុងរយៈពេលយ៉ាងឆាប់បំផុត ត្រឹម ១៥ថ្ងៃក្រោយពេលដេញថ្លៃនោះ ដោយត្រូវប្រកាសជូនដំណឹងក្នុងពេលនោះភ្លាមហើយមិនបាច់បិទផ្សាយជូនដំណឹងដូចមានចែងក្នុងមាត្រា ៤ទេ។

បើការដេញថ្លៃលើកក្រោយនេះ នៅតែគ្មានជនណាហ៊ានអោយថ្លៃតាមថ្លៃឈ្នួលដែលបានកំណត់ដាក់អោយដេញទៀតនោះ ប្រធាននាយកដ្ឋានជលផលអាចធ្វើកិច្ចសន្យាជួលឡូត៍នេសាទជូនអ្នកនេសាទតាមថ្លៃព្រមព្រៀង ក្រោយពីមានការយល់ព្រមពីក្រសួងកសិកម្មដោយមិនបាច់ធ្វើសេចក្តីជូនដំណឹងដូចមានចែងក្នុងមាត្រា ៤និងមិនបាច់អនុវត្តការដេញថ្លៃដូចមានចែងក្នុងមាត្រា ៨ឡើយ ។

**មាត្រា១៦:** អង្គភាពនេសាទរដ្ឋដែលត្រូវបានក្រសួងកសិកម្មសំរេចប្រគល់ឡូត៍នេសាទអោយធ្វើអាជីវកម្ម និងសិក្សាស្រាវជ្រាវបច្ចេកទេស វិទ្យាសាស្ត្រខាងជលផលនោះ ត្រូវបង់ថ្លៃឈ្នួលឡូត៍នេសាទជូនរដ្ឋតាមការកំណត់របស់ក្រសួងកសិកម្ម និងក្រសួងហិរញ្ញវត្ថុ ។

**មាត្រា១៧:** អ្នកដែលដេញថ្លៃឡូត៍នេសាទបានហើយ ក្រោយពីមានសេចក្តីសំរេចរបស់ក្រសួងកសិកម្មអាចយកផ្នែកមួយចំនួននៃឡូត៍ដែលមានទិន្នផលសរុបមិនលើសពី ៥០% នៃទិន្នផលឡូត៍ទាំងមូលដែលជននោះមិនអាចមានលទ្ធភាពធ្វើអាជីវកម្ម ទៅជួលអោយអ្នកដទៃទៀតបានតាមថ្លៃព្រមព្រៀងដោយធ្វើកិច្ចសន្យា ។

ការជួលខាងលើនេះមិនអនុញ្ញាតអោយធ្វើការដេញថ្លៃបានឡើយទោះបីជាដេញថ្លៃតាមវិធីណាក៏ដោយ ។

អ្នកជួលបន្តអាចធ្វើអាជីវកម្មនេសាទបានលុះត្រាតែកិច្ចសន្យាខាងលើនេះ ត្រូវបានចុះទិដ្ឋាការពីការិយាល័យជលផលខេត្ត ក្រុង និងពីនាយកដ្ឋានជលផល ។

ក្នុងករណីដូចខាងលើនេះ ជនដែលដេញថ្លៃបាននៅតែទទួលខុសត្រូវលើកិច្ចសន្យាដដែល ។

**មាត្រា១៨:** អង្គភាពនេសាទរដ្ឋ ឬជនដែលបានទទួលសិទ្ធធ្វើអាជីវកម្មក្នុងឡូត៍នេសាទដោយមានលិខិតអនុញ្ញាតរួចហើយនោះ មានសិទ្ធិឃាត់ជាបណ្តោះអាសន្ននូវវត្ថុតាង និងជនល្មើសដែលចូលលួចធ្វើអាជីវកម្មនេសាទ ឬលួចកាប់ព្រៃលិចទឹកនៅក្នុងនាទីឡូត៍នេសាទដែលអង្គភាព ឬជននោះកាន់កាប់ ។

បន្ទាប់មកត្រូវបញ្ជូនជនល្មើស និងវត្ថុតាងជាបន្ទាន់ទៅកម្មាភិបាល បុគ្គលិកជលផលដែលមានសមត្ថកិច្ចនៅជិតនោះដើម្បីចុះពិនិត្យ និងធ្វើកំណត់ហេតុ ។

វត្ថុតាងដែលជាផលនេសាទ ត្រូវប្រគល់ជូនអង្គភាពនេសាទរដ្ឋ ឬជនដែលមានសិទ្ធិកាន់កាប់ឡូត៍នេសាទនោះវិញ ។

ករណីដូចខាងលើនេះមិនអនុញ្ញាតអោយអនុវត្តចំពោះការធ្វើនេសាទជាលក្ខណៈគ្រួសារនៅក្នុងរយៈពេលបិទនេសាទលើឡូត៍នេសាទនោះទេ។

**មាត្រា១៩:** ក្នុងករណីឡូត៍នេសាទជាឡូត៍ដាយចាប់កូនត្រីប្រា ត្រូវអនុវត្តដូចខាងក្រោមៈ

១. ការដេញថ្លៃឡូត៍នេសាទមួយលើក១ ត្រូវបានកំណត់សំរាប់អោយធ្វើអាជីវកម្មនេសាទក្នុងរយៈពេលតែមួយរដូវនេសាទទេ។

២. ប្រាក់ធានាបណ្តោះអាសន្នត្រូវបានកំណត់ស្មើនឹងថ្លៃឈ្នួលឡូត៍នេសាទ ដែលបានកំណត់ដាក់អោយដេញថ្លៃ។

៣. ប្រាក់ធានាស្ថាពរត្រូវបានកំណត់ស្មើនឹងថ្លៃឈ្នួលឡូត៍នេសាទដែលដេញបាន។

ក្រៅពីល័ក្ខខ័ណ្ឌទាំង៣ចំណុចខាងលើនេះត្រូវអនុវត្តតាមបទបញ្ញាទាំងឡាយដែលមានចែងក្នុងអនុក្រឹត្យនេះដូចឡូត៍នេសាទផ្សេងៗទៀតដែរ។

**មាត្រា២០:** ការធ្វើអាជីវកម្មនេសាទសិប្បកម្មនៅទឹកសាប អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត។

លិខិតអនុញ្ញាតខាងលើនេះអាចចេញអោយបាន ក្រោយពីបានពិនិត្យ និងសំរេចលើពាក្យសុំធ្វើអាជីវកម្មនេសាទដែលបញ្ជាក់ពីប្រភេទ និងទំហំឧបករណ៍សំភារៈនេសាទព្រមទាំងទីកន្លែង និងពេលវេលាដែលធ្វើនេសាទនៅការិយាល័យជលផលខេត្ត ក្រុងដែលមានដែននេសាទដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោមៈ

១. បង្កាន់ដៃបង់ប្រាក់ថ្លៃឈ្នួលដែលនេសាទដែលត្រូវការពារ សំរាប់ធ្វើអាជីវកម្មក្នុងមួយរដូវនេសាទ។

២. កិច្ចសន្យាគោរពអោយបានត្រឹមត្រូវតាមបទបញ្ញាដែលមានចែងក្នុងក្រឹត្យ ច្បាប់ស្តីពីការគ្រប់គ្រងវិស័យជលផល និងក្នុងលិខិតអនុញ្ញាតអោយធ្វើអាជីវកម្មនេសាទ។

ក្នុងករណីចាំបាច់នាយកដ្ឋាន ឬការិយាល័យជលផលខេត្ត ក្រុងអាចអោយធ្វើកិច្ចសន្យាផ្សេងៗបន្ថែម ទៀត។

**មាត្រា២១:** ក្រៅពីការធ្វើនេសាទជាលក្ខណៈគ្រួសារ ការធ្វើអាជីវកម្មនេសាទសមុទ្រទាំងអស់អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត។

លិខិតអនុញ្ញាតខាងលើនេះអាចចេញអោយបាន ក្រោយពីបានពិនិត្យ និងសំរេចលើពាក្យសុំធ្វើអាជីវកម្មនេសាទសមុទ្រដែលបញ្ជាក់ពីប្រភេទ និងទំហំឧបករណ៍ សំភារៈនេសាទព្រមទាំងទីកន្លែង និងពេលវេលាដែលធ្វើនេសាទនៅការិយាល័យជលផលខេត្ត ក្រុងដែលមានដែននេសាទ ឬនាយកដ្ឋានជលផលដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោមៈ

១. បង្កាន់ដៃបង់ប្រាក់ថ្លៃឈ្នួលដែននេសាទសមុទ្រ សំរាប់ធ្វើអាជីវកម្មនេសាទក្នុងរយៈពេលមួយឆ្នាំ ។

២. លិខិតអនុញ្ញាតអោយប្រើប្រាស់ ទូក ឬកាណូត ។

៣. កិច្ចសន្យាគោរពអោយបានត្រឹមត្រូវតាមបទបញ្ញាដែលមានចែងក្នុងក្រឹត្យ ច្បាប់ស្តីពីការគ្រប់គ្រងវិស័យជលផល និងក្នុងលិខិតអនុញ្ញាតអោយធ្វើអាជីវកម្មនេសាទ ។

ក្នុងករណីចាំបាច់ នាយកដ្ឋាន ឬការិយាល័យជលផលខេត្ត ក្រុងអាចអោយធ្វើកិច្ចសន្យាផ្សេងៗបន្ថែមទៀត ។

**មាត្រា២២:** ថ្លៃឈ្នួលដែននេសាទដែលត្រូវការពារនៅទឹកសាប និងដែននេសាទសមុទ្រត្រូវបានគិតបញ្ចូលទាំងពន្ធអាជីវកម្មតែម្តងដោយយកតាមតារាងកំណត់ថ្លៃឈ្នួលដែននេសាទ ដែលត្រូវការពារនៅទឹកសាប និងតារាងកំណត់ថ្លៃឈ្នួលដែននេសាទសមុទ្រ ដូចមានឯកសារឧបសម្ព័ន្ធភ្ជាប់ជាមួយ ។

ការយកថ្លៃឈ្នួលត្រូវគិតចេញជាថ្លៃសរុបនៃផលនេសាទដែលបានកំណត់ក្នុងតារាងនេះ ដោយផ្អែកលើថ្លៃផលនេសាទដែលរដ្ឋបានកំណត់ ។

ចំពោះជនបរទេសដែលបានការយល់ព្រមពីក្រុមប្រឹក្សារដ្ឋមន្ត្រី អោយធ្វើអាជីវកម្មនេសាទការយកថ្លៃឈ្នួលដែននេសាទសមុទ្រ ត្រូវបានកំណត់តាមការព្រមព្រៀងក្នុងកិច្ចសន្យាដោយឡែករវាងនាយកដ្ឋានជលផល និងភាគីបរទេស ។

**មាត្រា២៣:** ប្រាក់ថ្លៃឈ្នួលដែននេសាទគ្រប់ប្រភេទត្រូវបានបែងចែកដូចខាងក្រោមៈ

១. សំរាប់ពន្ធអាជីវកម្មដែលត្រូវបង់ជូនសាខា ឬការិយាល័យពន្ធខេត្ត ក្រុងចំនួន ៥% ។

២. សំរាប់ថ្លៃឈ្នួលដែននេសាទដែលត្រូវបង់ជូននាយកដ្ឋាន ឬការិយាល័យជលផលខេត្តក្រុងចំនួន៩៥% ។

**មាត្រា២៤:** ប្រាក់ថ្លៃឈ្នួលដែននេសាទដូចមានចែងក្នុងមាត្រា ២៣ ចំណុច ២ ត្រូវបានធ្វើការបែងចែកដូចខាងក្រោមៈ

១. សំរាប់ចំណូលថវិកាខេត្ត ក្រុងចំនួន ៤០%ក្នុងនេះត្រូវបែងចែកជូនការិយាល័យជលផលខេត្ត ក្រុង សំរាប់កិច្ចថែរក្សាការពារ និងរៀបចំដែននេសាទចំនួន ៥% ។

២. ចំណូលថវិកាមជ្ឈិម ៦០% ក្នុងនោះក្រសួងផែនការ និងក្រសួងហិរញ្ញវត្ថុត្រូវគ្រោងទុកចំនួន ១០% ជូននាយកដ្ឋានជលផលសំរាប់កិច្ចថែរក្សា ការពារ និងរៀបចំដែននេសាទ ។

ចំពោះចំណូល ៦០% ខាងលើនេះត្រូវបង់ចូលគណនីរបស់នាយកដ្ឋានជលផល ហើយនាយកដ្ឋានជលផលត្រូវបង់ចូលថវិកាមជ្ឈិមជាបន្ទាន់ ។

**មាត្រា២៥:** ប្រាក់ពិន័យនិងប្រាក់លក់វត្ថុតាងត្រូវបានបែងចែកដូចខាងក្រោម:

១. បង់ចូលថវិកាខេត្ត ៤០%

២. បង់ចូលថវិកាមជ្ឈិម ៦០%

ចំពោះចំណូល ៦០% ខាងលើនេះត្រូវបង់ចូលគណនីរបស់នាយកដ្ឋានជលផល ហើយនាយកដ្ឋានជលផលត្រូវបង់ចូលថវិកាមជ្ឈិមជាបន្ទាន់ ។

**មាត្រា២៦:** ជនទាំងឡាយណាដែលមានស្នាដៃក្នុងការបង្ក្រាបបទល្មើសជលផល ត្រូវបានសរសើរជូនរង្វាន់ ។

ក្រសួងហិរញ្ញវត្ថុត្រូវកំណត់ថវិការដ្ឋ ដើម្បីជូនរង្វាន់ចំពោះអ្នកមានស្នាដៃ និងអ្នកផ្តល់ពត៌មានចំនួន ១០%នៃប្រាក់ដែលបានពីបទល្មើស ។

**មាត្រា២៧:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា២៨:** ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីក្រសួងកសិកម្មក្រសួងពាក់ព័ន្ធនឹងគណ:កម្មាធិការប្រជាជនខេត្ត ក្រុងត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា២៩:** អនុក្រឹត្យនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណ: ។

ភ្នំពេញថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៨៩

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

ឯកសារឧបសម្ព័ន្ធលេខ ១ ភ្ជាប់ជាមួយអនុក្រឹត្យ ស្តីពីការជួលដែននេសាទទឹកសាប និងសមុទ្រ អោយធ្វើអាជីវកម្ម

# តារាងស្តីពីការកំណត់ថ្លៃឈ្នួលដែននេសាទទឹកសាបដែលត្រូវការពារ

ឯកតាគិត: គក្រ

| ល.រ | ប្រភេទឧបករណ៍នេសាទ សិប្បកម្ម | ឯកតា | ចំនួន | បរិមាណត្រីលេខ ១ ស្រស់ ដែលត្រូវបានកំណត់យកភាគរយ | |
|---|---|---|---|---|---|
| | | | | តំបន់មេគង្គនិងបាសាក់ | តំបន់បឹងទន្លេសាប និងដងទន្លេសាប |
| ១ | - នាមប្រើទូក ១ "មាត់តូចជាង ១០ម" | វង់ | ១ | ៩០ | ១១១ |
| ២ | - ម៉ាញ់ "មាត់តូចជាង ២៥ម" | វង់ | ១ | ២២៥ | ១៥០ |
| ៣ | - ឆៃ៉ា | វង់ | ១ | ១៣៥ | ១៥០ |
| ៤ | - មង "អួសដៃ" | ម៉ែត្រ | ១ | ១,១០ | ១,១០ |
| ៥ | - មង "មងក្រឡាតូចជាង ៤.៥ ស.ម" | ម៉ែត្រ | ១ | ០,២៥ | ០,៣០ |
| ៦ | - មង "ក្រឡាពី៤.៥សម ឡើងទៅ | ម៉ែត្រ | ១ | ០,៣៥ | ០,៤៥ |
| ៧ | - ជន | វង់ | ១ | ១១,១០ | ១៦,៦៥ |
| ៨ | - ឈ្នក់ "ជ្រុងនីមួយ១ | ម៉ែត្រក្រឡា | ១ | ១,៦៥ | ៤,៤៥ |

| | | | | | |
|---|---|---|---|---|---|
| | លើសពី ២ម" | | | | |
| ៩ | - សំណាញ់បណ្ដោយ លើសពី ៥ម | វង់ | ១ | ២២ | ៣៣,៣៥ |
| ១០ | - អួន ឬ មង ហ៊ុំ | ម៉ែត្រ | ១ | ២,២៥ | ៣,៣៥ |
| ១១ | - អួនប្រយុង ឬស្រុង | ម៉ែត្រ | ១ | ២,៨០ | ៥,៥៥ |
| ១២ | - ថ្នង "មាត់លើសពី២ ម" | វង់ | ១ | ៥,៥០ | ១១,១០ |
| ១៣ | - លប ទ្រូ សៃយឺន " កំពស់លើសពី០,៨ ម និង បន្ទាត់ផ្ចិតលើសពី ០,៣ម | គ្រឿង | ១ | ៤,៥០ | ៦,៦៥ |
| ១៤ | - លប ទ្រូ សៃយឺន "រុម ផ្សំព្រួល" | ម៉ែត្រ | ១ | ១,១០ | ១,៦៥ |
| ១៥ | - លប ណ ឬ វាវ - "បណ្ដោយតិចជាង- ៥០០ម | ម៉ែត្រ | ១ | | ១,៦៥ |
| ១៦ | - ឡើ | គ្រឿង | ១ | ០,៩០ | ០,៩០ |
| ១៧ | - ប៉ោង | គ្រឿង | ១ | ៣,៣០ | ៣,៣០ |
| ១៨ | - តុម | គ្រឿង | ១ | ១,១០ | ១,១០ |
| ១៩ | - ឈ្នាងត្រាំ | គ្រឿង | ១ | ៣,៣០ | ៣,៣០ |
| ២០ | - ឈ្នាងកង | គ្រឿង | ១ | ៥,៥០ | ៥,៥៥ |
| ២១ | - ប្រម | វង់ | ១ | ២,២០ | ២,២០ |
| ២២ | - អញ្ចង "បណ្ដោយ- លើសពី ៣ ម" | វង់ | ១ | ៥,៥៥ | ៥,៥៥ |
| ២៣ | - សន្ទូចបង្កៃត្រីធំ | ផ្លែ | ១ | ០,២០ | ០,៤៥ |
| ២៤ | - សន្ទូចរនង | គ្រឿង | ១ | ០,១០ | ០,៣០ |

ភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៨៩

ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ប៊ុន អ៊ុយ

ឯកសារឧបសម្ព័ន្ធ លេខ២ ភ្ជាប់ជាមួយអនុក្រឹត្យ ស្តីពីការជួលដែននេសាទទឹកសាប និងសមុទ្រអោយធ្វើអាជីវកម្ម

## តារាងស្តីពីការកំនត់ថ្លៃឈ្នួល ដែននេសាទសមុទ្រ

| ល.រ | ប្រភេទឧបករណ៍នេសាទ | ឯកតា | ចំនួន | បរិមាណផលនេសាទ ស្រស់ដែលត្រូវបានកំណត់យកវិភាគទាន ឯកតាគិត: "គីឡូក្រាម" | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បង្គា | | | ត្រីចំរុះ | | | មឹក | ក្តាម | ក្រែងឈាម |
| | | | | លេខ១ | លេខ ២ | លេខ៣ | លេខ១ | លេខ២ | លេខ៣ | | | |
| ១ | អួនអួស | សេះ | ១ | ០,៥៥ | ១.៦៥ | ២.២០ | ៥.៥៥ | | ២២.២០ | | | |
| ២ | អួនខ្វៃ | ម៉ែត្រ | ១ | | | | | ១០ | | | | |
| ៣ | អួនទិតនិងអួនផ្សេង១ទៀត | ម៉ែត្រ | ១ | | | | | ១៣.៣០ | | | | |
| ៤ | អងបង្គារ | ម៉ែត្រ | ១ | | ០,០៤៥ | | | | | | | |
| ៥ | មងក្បក | ម៉ែត្រ | ១ | | | | | ០,៤៥ | | | | |
| ៦ | មងត្រីផ្សេង១ទៀត | ម៉ែត្រ | ១ | | | | ០,៤៥ | | | | | |
| ៧ | ប៉ក់ | ប៉ក់ | ១ | | | | ១,៤៤៥ | | | | | |
| ៨ | សំណាច់បណ្តោយលើសពី៦ម | វង់ | ១ | | | | | ២២.២០ | | | | |
| ៩ | មងក្តាម | ម៉ែត្រ | ១ | | | | | | | | ០,០៣ | |
| ១០ | ឈ្នក់ក្តាមចំនួនច្រើនជាង ៣០ | ឈ្នក់ | ១ | | | | | | | | ០,៦៥ | |
| ១១ | លបមឹក | លប | ១ | | | | | | | ១,៩ | | |
| ១២ | ឈ្នាងចាប់ក្រែងឈាម | ឈ្នាង | ១ | | | | | | | | | ៨,៩ |
| ១៣ | សន្ទូចលើសពី ១០ផ្លែ | ផ្លែ | ១ | | | | ១.១០ | | | | | |

ឧបករណ៍នេសាទដែលអាចអនុញ្ញាតអោយធ្វើអាជីវកម្ម ក្នុងដែននេសាទសមុទ្រ មួយចំនួនទៀត ដែលបច្ចុប្បន្នមិនទាន់មានសកម្មភាពធ្វើអាជីវកម្មនេសាទនោះ មិនទាន់កំណត់ចូលក្នុងតារាងនេះនៅឡើយ ។

ភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៨៩

ជ.រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ប៊ុន អ៊ុយ